**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

**សំណុំរឿង**

លេខ : ០៥៦/០១០/២០០២

ចុះថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ២០០២

**សេចក្ដីសម្រេច**

លេខ : ០៥០/០០១/២០០៣ កបធ.ច

ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០០៣

# ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ២០០១ ប្រកាសឱ្យប្រើច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលឃុំ-សង្កាត់
- បានឃើញលិខិតចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ២០០២ របស់សមាជិកសភា ១៣រូប នៃគណបក្ស សម រង្ស៊ី ជូនឯកឧត្ដមប្រធាន **ជា ឈិន** ស្នើសុំឱ្យក្រុមប្រឹក្សាធម្មនុញ្ញបកស្រាយមាត្រា ៣០ នៃច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ហើយដែលក្រុមប្រឹក្សាធម្មនុញ្ញបានទទួលនៅថ្ងៃទី ២៦ ខែ ឆ្នាំ ដដែល ។

**ក្រោយពីបានស្ដាប់របាយការណ៍របស់សមាជិករាយការណ៍**

**ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ**

- យល់ឃើញថា សមាជិកសភាចំនួន ១៣រូប បានស្នើមកក្រុមប្រឹក្សាធម្មនុញ្ញក្នុងចំនួនលើសពីមួយភាគដប់ ( ១/១០ x ១២២ ) ឱ្យបកស្រាយមាត្រា ៣០ នៃច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ។ សំណើនេះស្របតាមមាត្រា ១៣៦ ថ្មី និង មាត្រា ១៤១ ថ្មី នៃរដ្ឋធម្មនុញ្ញ ។ ដូចនេះក្រុមប្រឹក្សាធម្មនុញ្ញអាចយកសំណើនេះមកពិនិត្យបាន ។

- យល់ឃើញថា ក្រុមប្រឹក្សាឃុំ សង្កាត់ ម្យ៉ាងជាអង្គការតំណាងប្រជាពលរដ្ឋក្នុងឃុំ សង្កាត់របស់ខ្លួន ម្យ៉ាងទៀតជាភ្នាក់ងារតំណាងរដ្ឋដែលស្ថិតនៅក្រោមការចាត់តាំង ឬ ការប្រគល់អំណាចរបស់អាជ្ញាធររដ្ឋ ( មាត្រា ៤២ ) ។ ក្នុងឋានៈជាតំណាងប្រជាពលរដ្ឋ ក្រុមប្រឹក្សាឃុំ សង្កាត់មានតួនាទីធំធេងក្នុងការបំរើកិច្ចការមូលដ្ឋាន រៀបចំសណ្តាប់ធ្នាប់សាធារណៈ សេវាសាធារណៈ ផាសុកភាព និង សុខុមាលភាព អភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ច ថែរក្សាបរិស្ថាន ។ល។ ក្នុងក្របខ័ណ្ឌនយោបាយវិមជ្ឈការ ។ ក្នុងឋានៈជាភ្នាក់ងារតំណាងរដ្ឋ ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវគោរព និង អនុវត្តតាមការណែនាំថ្នាក់លើ តាមលំដាប់ឋានានុក្រម ។
- យល់ឃើញថា មាត្រា ៣០ ( វាក្យខ័ណ្ឌទី១ និង ទី២ ) នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ដែលបានតម្រូវឱ្យក្រុមប្រឹក្សាឃុំ សង្កាត់ រៀបចំជ្រើសរើសមេភូមិ ។ មេភូមិត្រូវរៀបចំចាត់តាំងអនុប្រធានភូមិ និង សមាជិកជាជំនួយការ ( លក្ខណៈគ្រប់គ្រាន់ ) បានតម្រូវយ៉ាងច្បាស់ថា ( វាក្យខ័ណ្ឌទី៣ ) : " រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវចេញសេចក្តីណែនាំអំពីបែបបទ នីតិវិធី នៃការជ្រើសរើសមេភូមិ ការចូលកាន់តំណែង ការផ្លាស់ប្តូរមេភូមិ និងការតែងតាំងជំនួយការភូមិ " ដែលជាបទបញ្ញត្តិមានលក្ខណៈចាំបាច់ ។ មាត្រា ៨៦ បានបញ្ជាក់បន្ថែមក្នុងអន្តរប្បញ្ញត្តិថា ត្រូវធ្វើ ... " តាមបែបបទនីតិវិធីដូចមានចែងក្នុងមាត្រា ៣០ នៃច្បាប់នេះ " ។
- យល់ឃើញថា ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ មិនបានកំណត់រយៈពេលឱ្យរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ចេញសេចក្តីណែនាំក្នុងរឿងនេះទេ ប៉ុន្តែការពិនិត្យបានបង្ហាញឱ្យឃើញថា មានការកំណត់រយៈពេលសម្រាប់រឿងផ្សេងៗឯទៀត មានយ៉ាងយូរត្រឹម ០៦ ខែ ។ ការពិនិត្យបន្ថែមបានបង្ហាញឱ្យឃើញថា ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ បានតម្រូវឱ្យក្រសួងមហាផ្ទៃចេញសេចក្តីណែនាំចំនួនប្រហែលម្ភៃសម្រាប់បង្កើនប្រសិទ្ធភាពនៃនយោបាយវិមជ្ឈការនេះ ។
- យល់ឃើញថា " គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ " ដែលមានរដ្ឋមន្ត្រីក្រសួងមហាផ្ទៃជាប្រធាន បង្កើតដោយមាត្រា ៨៧ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ក្នុងគោលដៅបង្កលក្ខណៈសម្បត្តិងាយស្រួលដល់នយោបាយវិមជ្ឈការមានសមត្ថកិច្ចគ្រប់គ្រាន់ ( មាត្រា ៨៨ ) ក្នុងការដោះស្រាយ ឬ ជំរុញឱ្យមានការណែនាំក្នុងរយៈពេលសមស្របមួយ ។
- យល់ឃើញថា តាមមាត្រា ៤៤ ក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងឋានៈជាភ្នាក់ងាររដ្ឋ អាចត្រូវបានទទួលប្រតិភូកម្មអំណាចពីសំណាក់អាជ្ញាធររដ្ឋសម្រាប់កិច្ចការអនុវត្តន៍ វៀរលែងតែវិស័យដែលមានចែងច្បាស់ក្នុងមាត្រា ៤៥ ដែលជាសមត្ថកិច្ចរបស់អាជ្ញាធរកណ្តាល ។
- យល់ឃើញថា ក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងឋានៈជាភ្នាក់ងារតំណាងរដ្ឋត្រូវស្នើសុំការណែនាំគោលការណ៍នៃ

ការរៀបចំជ្រើសរើសមេភូមិពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ទោះបីក្នុងលក្ខណៈជាការជ្រើសរើសបណ្តោះអាសន្នក៏ដោយ ។ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃមានកាតព្វកិច្ចត្រូវឆ្លើយតបចំពោះសំណូមពរនេះក្នុងរយៈពេលមួយសមស្រប ។

## **សម្រេច**

**មាត្រា ១** : មាត្រា ៣០ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ត្រូវបកស្រាយតាមមូលបទខាងលើនេះ ។

**មាត្រា ២** : សេចក្តីសម្រេចនេះធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៥ ខែ មករា ឆ្នាំ២០០៣ នាសម័យប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច ។

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០០៣

**ជ.ក្រុមប្រឹក្សាធម្មនុញ្ញ**

**ប្រធាន**

**ហត្ថលេខា និង ត្រា**

**ប៊ិន ឈិន**